ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
គណៈកម្មាធិការប្រឡងថ្នាក់ជាតិ
លេខ: ១៥៨ គ.ប.ជ សរណ

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងថ្នាក់ជាតិជ្រើសរើសចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល

គណៈកម្មាធិការប្រឡងថ្នាក់ជាតិ សូមជម្រាបដល់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល និងនិស្សិតទាំងអស់ឱ្យបានជ្រាបថា សម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ ខាងមុខនេះ គណៈកម្មាធិការ-ប្រឡងថ្នាក់ជាតិនឹងធ្វើការប្រឡងថ្នាក់ជាតិ ជ្រើសរើសនិស្សិតដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល តាមចំនួន និងលក្ខខណ្ឌដូចខាងក្រោម៖

**១-លក្ខខណ្ឌនៃការជ្រើសរើស:**

*បេក្ខជនត្រូវ:*

- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ ព្រឹត្តប័ត្រពិន្ទុនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចេញដោយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅនៃក្រសួងអប់រំ យុវជន និងកីឡា ឬ មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ-ខេត្ត ឬ សញ្ញាបត្រដែលមានតម្លៃស្មើ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ឬ គណៈកម្មាធិការវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា។
- មាននិទ្ទេសពិន្ទុសរុបនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទាបបំផុតត្រឹម C ។
- បេក្ខជនដែលប្រឡងជាប់ចូលរៀនថ្នាក់ជាតិសម្រាប់វិស័យសុខាភិបាល ក្នុងឆ្នាំសិក្សា២០១៤-២០១៥ មានសិទ្ធទទួលបានអាហារូបករណ៍ចំពោះតែបេក្ខជនដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំសិក្សា២០១៣-២០១៤ តែមួយឆ្នាំប៉ុណ្ណោះ។ និស្សិតដែលបានទទួលអាហារូបករណ៍ជំនាញដទៃទៀតរួចហើយ មិនមានសិទ្ធទទួលអាហារូបករណ៍សម្រាប់វិស័យសុខាភិបាលទេ តែមានសិទ្ធចូលរៀនតាមរយៈការបង់ថ្លៃសិក្សា។
- ជ្រើសរើសគ្រឹះស្ថានបណ្តុះបណ្តាល និងមុខជំនាញដែលខ្លួនចង់ចូលរៀន តាមរយៈការដាក់ពាក្យសុំប្រឡងជ្រើសរើសចូលរៀនថ្នាក់ជាតិ។

**២-ចំនួនជ្រើសរើស:**

គណៈកម្មាធិការប្រឡងថ្នាក់ជាតិ នឹងធ្វើការជ្រើសរើសទៅតាមលទ្ធផលនៃការប្រឡង ដោយកំណត់យកតាមលំដាប់ពិន្ទុពីខ្ពស់មកទាប និងតាមការជ្រើសរើសរបស់និស្សិតទៅតាមគ្រឹះស្ថានបណ្តុះបណ្តាល សម្រាប់ឆ្នាំសិក្សា២០១៤-២០១៥ ដែលមានចំនួនសរុប ២៥១៩នាក់ ដោយបែងចែកតាមចំនួនដូចខាងក្រោម៖

- ថ្នាក់វេជ្ជបណ្ឌិតទូទៅ សរុបចំនួន ៧៥៨នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម: ៤៥

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ៣០០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍ ចំនួន៣០នាក់)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ៩០នាក់
- សាកលវិទ្យាល័យអន្តរជាតិ ចំនួន ១៨០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ១០៨នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ៨០នាក់

❖ ថ្នាក់បរិញ្ញាបត្រឱសថ សរុបចំនួន ៥០៤នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម:
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ១៥៤នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍ ចំនួន១៥នាក់)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ៤០នាក់
- សាកលវិទ្យាល័យអន្តរជាតិ ចំនួន ១១០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ១១០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ៥០នាក់
- វិទ្យាស្ថានបូលីណូ ខេត្តកំពង់ឆ្នាំង ចំនួន ៤០នាក់

❖ ថ្នាក់ទន្តបណ្ឌិតទូទៅ សរុបចំនួន ៤៣១នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម:
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ១២១នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍ ចំនួន១២នាក់)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ៤០នាក់
- សាកលវិទ្យាល័យអន្តរជាតិ ចំនួន ៩០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ៩០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ៥០នាក់
- វិទ្យាស្ថានបូលីណូ ខេត្តកំពង់ឆ្នាំង ចំនួន ៤០នាក់

❖ ថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក សរុបចំនួន ៤៨០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម:
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ១១០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍ ចំនួន១១នាក់)
- សាកលវិទ្យាល័យអន្តរជាតិ ចំនួន ៨០នាក់
- សាកលវិទ្យាល័យឡាយហ្វ ចំនួន ៤០នាក់
- សាកលវិទ្យាល័យចេនឡា ចំនួន ៤០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ៨០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ៥០នាក់
- វិទ្យាស្ថានបូលីណូ ខេត្តកំពង់ឆ្នាំង ចំនួន ៤០នាក់
- សាកលវិទ្យាល័យកំពង់ចាម ចំនួន ៤០នាក់

❖ ថ្នាក់បរិញ្ញាបត្រឆ្មប ៖ សរុបចំនួន ២៦៦នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម:
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ៦៦នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍ ចំនួន០៦នាក់)
- សាកលវិទ្យាល័យអន្តរជាតិ ចំនួន ៤០នាក់

- សាកលវិទ្យាល័យចេនឡា ចំនួន ៤០នាក់
- សាកលវិទ្យាល័យឡាយហ្វ ចំនួន ៤០នាក់
- វិទ្យាស្ថានបូលីណូ ខេត្តកំពង់ឆ្នាំង ចំនួន ៤០នាក់
- សាកលវិទ្យាល័យកំពង់ចាម ចំនួន ៤០នាក់

❖ ថ្នាក់បរិញ្ញាបត្រសុខភាពសាធារណៈ: សរុបចំនួន ៨០នាក់
ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម:
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ៨០នាក់

(ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍ ចំនួន០៨នាក់)

បេក្ខជនដែលមានពិន្ទុជាប់តាមចំនួនសរុបផ្នែកនីមួយៗខាងលើ ពុំមានសិទ្ធតវ៉ាសុំចូលរៀននៅគ្រឹះស្ថានបណ្តុះបណ្តាលណាមួយ លើសពីចំនួនបែងចែកដែលកំណត់តាមគ្រឹះស្ថាននីមួយៗ និងខុសពីជម្រើសរបស់ខ្លួនឡើយ។

ដោយឡែកគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលទាំងអស់ខាងលើ ពុំមានសិទ្ធតវ៉ាសុំយកនិស្សិតបន្ថែមដើម្បីបង្គ្រប់ចំនួនបែងចែកខាងលើឡើយ ក្នុងករណីដែលនិស្សិតបានប្រឡងជាប់ថ្នាក់ជាតិ តែមិនព្រមចូលរៀននៅគ្រឹះស្ថានបណ្តុះបណ្តាលទាំងនោះ។

គណៈកម្មាធិការប្រឡងថ្នាក់ជាតិនឹងមិនជ្រើសរើសនិស្សិតបន្ថែមដើម្បីបំពេញចំនួនកំណត់តាមគ្រឹះស្ថានបណ្តុះបណ្តាលខាងលើ ក្នុងករណីដែលនិស្សិតប្រឡងជាប់ពុំបានធ្វើការជ្រើសរើសចូលរៀននៅគ្រឹះស្ថានទាំងនោះ។

☞ ក្នុងករណីបេក្ខជន/បេក្ខនារីដាក់ពាក្យសុំប្រឡងជ្រើសរើសចូលរៀនថ្នាក់ជាតិមិនគ្រប់ចំនួនតាមការផ្តល់ខាងលើ គណៈកម្មាធិការប្រឡងថ្នាក់ជាតិរក្សាសិទ្ធក្នុងការផ្លាស់ប្តូរពីការប្រឡងមកការជ្រើសរើសតាមព្រឹត្តិបត្រពិន្ទុនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយជ្រើសរើសយោងទៅតាមលំដាប់ពិន្ទុពីខ្ពស់មកទាប ។

## ៣-មុខវិជ្ជា និងរយៈពេលប្រឡង

- ជីវៈវិទ្យា (Biology) រយៈពេលធ្វើ ១ ម៉ោង ៣០ នាទី
- គីមីវិទ្យា (Chemistry) រយៈពេលធ្វើ ១ ម៉ោង ៣០ នាទី
- គណិតវិទ្យា (Mathematic) រយៈពេលធ្វើ ២ ម៉ោង

ទំរង់វិញ្ញាសា៖ ដូចប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## ៤-សំណុំលិខិតដែលត្រូវបំពេញ

-បង្កាន់ដៃទទួលពាក្យ..........១ច្បាប់
-ពាក្យសុំចុះឈ្មោះប្រឡង..........២ច្បាប់
-ប្រវត្តិរូបសង្ខេបមានបិទរូបថតថ្មី ( ៤ x ៦)..........២ច្បាប់
-រូបថត ៤ x ៦ (ពណ៌ ថ្មី)..........៣សន្លឹក
-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ ព្រឹត្តប័ត្រពិន្ទុនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយ-ភូមិ ចេញដោយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅនៃក្រសួងអប់រំ យុវជន និងកីឡា ឬ មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ-ខេត្ត ឬ សញ្ញាបត្រដែលមានតម្លៃស្មើ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ឬ គណៈកម្មាធិការវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សាច្បាប់ដើម ឬ ថតចម្លងដោយមានបញ្ជាក់ពីសាលារាជធានីភ្នំពេញ-ខេត្ត(ភ្ជាប់មកជាមួយនូវច្បាប់ដើមដើម្បីផ្ទៀងផ្ទាត់)..........២ច្បាប់

## ៥-ទីកន្លែងដាក់ពាក្យ

ចាប់ទទួលពាក្យពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤ ម៉ោង ៥ល្ងាច នៅតាមសាកលវិទ្យាល័យ ដែលបេក្ខជនចាត់ទុកជាអាទិភាពទី១ ដូចខាងក្រោម:/៣.

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នៃក្រសួងសុខាភិបាល សម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្រោយពីប្រឡងជាប់ចូលរៀនផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ បរិញ្ញាបត្រគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មប និងបរិញ្ញាបត្រសុខភាពសាធារណៈ
- សាកលវិទ្យាល័យអន្តរជាតិ សម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅសាកលវិទ្យាល័យអន្តរជាតិ ក្រោយពីប្រឡងជាប់ចូលរៀនផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្រឆ្មប
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ សម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ក្រោយពីប្រឡងជាប់ចូលរៀនផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តវេទនសាស្ត្រ
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ សម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ក្រោយពីប្រឡងជាប់ចូលរៀនផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ និងបរិញ្ញាបត្រគិលានុបដ្ឋាក
- សាកលវិទ្យាល័យឡាយហ្វ សម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅសាកលវិទ្យាល័យឡាយហ្វ ក្រោយពីប្រឡងជាប់ចូលរៀនផ្នែកបរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្រឆ្មប
- សាកលវិទ្យាល័យចេនឡាសម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅសាកលវិទ្យាល័យចេនឡា ក្រោយពីប្រឡងជាប់ចូលរៀនផ្នែកបរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្រឆ្មប
- វិទ្យាស្ថានបូលីណូសម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅវិទ្យាស្ថានបូលីណូក្រោយពីប្រឡងជាប់ចូលរៀនផ្នែកឱសថសាស្ត្រ ទន្តវេទនសាស្ត្រ បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្រឆ្មប
- សាកលវិទ្យាល័យន័រតុន សម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅសាកលវិទ្យាល័យន័រតុន ក្រោយពីប្រឡងជាប់ចូលរៀនផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ និងបរិញ្ញាបត្រគិលានុបដ្ឋាក
- សាកលវិទ្យាល័យកំពង់ចាម សម្រាប់និស្សិតដែលមានបំណងបន្តការសិក្សានៅសាកលវិទ្យាល័យកំពង់ចាម ក្រោយពីប្រឡងជាប់ចូលរៀនផ្នែកបរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្រឆ្មប

**៦-កាលបរិច្ឆេទ និងទីកន្លែងប្រឡង**

- កាលបរិច្ឆេទប្រឡង: ថ្ងៃទី២០-២១ ខែធ្នូ ឆ្នាំ២០១៤
  -ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៤ ចាប់ពីម៉ោង ១៣:៣០នាទី ប្រឡងមុខវិជ្ជាជីវៈវិទ្យា (Biology) និងគីមីវិទ្យា (Chemistry)
  -ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៤ ចាប់ពីម៉ោង ១៣:៣០នាទី ប្រឡងមុខវិជ្ជាគណិតវិទ្យា (Mathematic)
- ទីកន្លែងប្រឡងសំណេរ: **សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

សំណុំលិខិតពាក្យសុំជ្រើសរើស និងព័ត៌មានផ្សេងៗទៀត សូមទាក់ទងនៅសាកលវិទ្យាល័យពាក់ព័ន្ធខាងលើ។

**សម្គាល់:**

- និស្សិតអាចជ្រើសរើសគ្រឹះស្ថានបណ្តុះបណ្តាលដែលខ្លួនចង់រៀន ដោយកំណត់ច្បាស់ពីអាទិភាពជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលដែលខ្លួនមានបំណងចូលរៀន ពីការប្រឡងជាប់ដូចខាងក្រោម:
  - ផ្នែកវេជ្ជសាស្ត្រ: និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលចំនួន ៣ដោយកំណត់ឱ្យច្បាស់លាស់ពីអាទិភាព ទី១ ទី២ និងទី៣
  - ផ្នែកឱសថសាស្ត្រ: និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាល ចំនួន ៣ ដោយកំណត់ឱ្យច្បាស់លាស់ពីអាទិភាព ទី១ ទី២ និងទី៣
  - ផ្នែកទន្តវេទនសាស្ត្រ: និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាល ចំនួន ៣ ដោយកំណត់ឱ្យច្បាស់លាស់ពីអាទិភាព ទី១ ទី២ និងទី៣

UHS

- ផ្នែកបរិញ្ញាបត្រគិលានុបដ្ឋាក: និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលចំនួន ៣ ដោយកំណត់ឱ្យច្បាស់លាស់ពីអាទិភាព ទី១ ទី២ និងទី៣
- ផ្នែកបរិញ្ញាបត្រឆ្មប: និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាល ចំនួន ៣ ដោយកំណត់ឱ្យច្បាស់លាស់ ពីអាទិភាព ទី១ ទី២ និងទី៣
- ថ្នាក់បរិញ្ញាបត្រសុខភាពសាធារណៈ: និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាល ចំនួន ១

- និស្សិតដែលជ្រើសរើសយកអាទិភាពចូលរៀនលើមុខជំនាញតែមួយ ឬគ្រឹះស្ថានបណ្តុះបណ្តាលតែមួយមានន័យថា សុខចិត្តបោះបង់ការសិក្សាក្នុងករណីដែលខ្លួនប្រឡង ឬជ្រើសរើសមិនជាប់ក្នុងចំនួនដែលបែងចែកទៅតាមគ្រឹះស្ថានទាំងនោះ។
- ក្នុងករណីរកឃើញថា បេក្ខជន/បេក្ខនារី ក្លែងបន្លំសញ្ញាបត្រ ឬឯកសារពាក់ព័ន្ធ ត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតចូលរៀននៅតាមសាកលវិទ្យាល័យដែលខ្លួនបានជ្រើសរើសនិងផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។
- ចំពោះករណីរកឃើញថាមានការប្រឡងជំនួស អ្នកប្រឡងជំនួសគេត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតដែលខ្លួនកំពុងរៀនបច្ចុប្បន្ន និងត្រូវទទួលទោសតាមច្បាប់ជាធរមាន។ ចំពោះបេក្ខជន/បេក្ខនារី ដែលឱ្យគេប្រឡងជួស ត្រូវចាត់ទុកថាធ្លាក់ដោយស្វ័យប្រវត្តិ។
- នៅថ្ងៃប្រឡងសំណេរបេក្ខជន/បេក្ខនារីត្រូវយកជាប់ជាមួយខ្លួននូវបង្កាន់ដៃទទួលពាក្យ និងប័ណ្ណសំគាល់ខ្លួន។
- ក្នុងករណី បេក្ខជន/បេក្ខនារី មិនមានបង្កាន់ដៃទទួលពាក្យនិងប័ណ្ណសំគាល់ខ្លួន នឹងមិនអនុញ្ញាតឱ្យចូលក្នុងបន្ទប់ប្រឡងឡើយ។

**ជ.គណៈកម្មាធិការប្រឡងថ្នាក់ជាតិ**
**សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល**
**ប្រធាន**

**សេង លឹមនៅ**

ចម្លងជូន ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសុខាភិបាល
- ក្រសួងអប់រំ យុវជន និងកីឡា
- គ្រឹះស្ថានពាក់ព័ន្ធ
- កាលប្បវត្តិ
- ឯកសារ លខ.គបជ